មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ជីវប្រវត្តិ អ្នកស្រី រឿង ខាន់
## សកម្មជនដីធ្លី



*"ការប្រឈមជាងគេបំផុតរបស់ខ្ញុំគឺការទាមទារដីឲ្យបងប្អូន ការតវ៉ាជាមួយរដ្ឋាភិបាល និងការចុះបញ្ជីដីសមូហភាព!"*

អ្នកស្រី រឿង ខាន់ កើតនៅឆ្នាំ១៩៦៤ មានស្រុកកំណើត និងរស់នៅភូមិប្រមេរ ឃុំប្រមេរ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។ គាត់ជាស្ត្រីមេម៉ាយចាប់តាំងពីឆ្នាំ១៩៨៤។ អ្នកស្រី ខាន់ ក៏ដូចជាអ្នកភូមិជនជាតិដើមភាគតិចដទៃទៀតនៅក្នុងឃុំប្រមេរ ប្រកបរបរតាមប្រពៃណីដូចជា ដងជ័រ កាប់ចម្ការវិលជុំធ្វើស្រែចំការ និងចិញ្ចឹមសត្វ ។ល។ នៅឆ្នាំ២០០៦ សហគមន៍ភូមិប្រមេរត្រូវ បានបង្កើតឡើង។ អ្នកស្រីខាន់ បានចូលរួមជាសមាជិកសហគន៍ចូលរួមប្រជុំពិភាក្សាលើបញ្ហាដីធ្លី និងធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច និងចាប់ផ្តើមចងក្រងបណ្តាញនៅតាមភូមិ ព្រមទាំងស្រង់អត្តសញ្ញាណជនជាតិដើមភាគតិចគួយដែលរស់នៅក្នុងឃុំប្រមេរ។ ស្ថិតិត្រូវស្រង់ និងដាក់ជូនអាជ្ញាធរឃុំ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ នៅឆ្នាំ២០០៧ ដើម្បីទទួលស្គាល់សហគមន៍។ នៅឆ្នាំ២០០៨ អ្នកស្រីខាន់ ត្រូវបានជ្រើសរើសជាគណៈកម្មាធិការសហគមន៍ភូមិប្រមេរ មានតួនាទីជាអនុប្រធានសហគមន៍ ទទួលបន្ទុកពិភាក្សា ពិគ្រោះយោបល់រាល់បញ្ហាសំខាន់ៗដែលកើតមាននៅក្នុងសហគមន៍។

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១១ រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បានចុះកិច្ចសន្យាប្រគល់ដីទំហំ ៩.០១៥ ហិកតា ឲ្យទៅក្រុមហ៊ុន ឡាន ហ្វេង ដើម្បីដាំដំណាំអាកាស្យា និងអំពៅ។ នៅខែមេសា ឆ្នាំ២០១២ ក្រុមហ៊ុនបានឈូសឆាយប៉ះពាល់ដល់ដីសហគមន៍ជនជាតិដើមភាគតិចក្នុងឃុំប្រមេរ និងប៉ះពាល់ជីវភាពរស់នៅរបស់ពួកគាត់ ជាពិសេសធ្វើឲ្យប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃណី ព្រមទាំងប្រាសាទបុរាណដែលបានបន្សល់ទុកតាំងពីរាប់ពាន់ឆ្នាំមុន។ នៅពេលក្រុមហ៊ុនធ្វើការឈូសឆាយ សហគមន៍បាននាំគ្នាទប់ស្កាត់ និងសុំអន្តរាគមន៍ពីអាជ្ញាធរឃុំ ស្រុក ខេត្ត រហូតដល់ដាក់ពាក្យប្តឹងទៅតុលាការ។ ទោះជាយ៉ាងនេះក៏ដោយ មិនដែលមានការយកចិត្តទុកដាក់ក្នុងការដោះស្រាយជូនប្រជាពលរដ្ឋទេ ផ្ទុយទៅវិញពួកគាត់បែរជាត្រូវបានចោទប្រកាន់ថា *"ប្រឆាំងនឹងគោលនយោបាយរបស់រដ្ឋាភិបាល ប្រឆាំងនឹងការអភិវឌ្ឍរបស់រដ្ឋ"* ទៅវិញ ចំណែកក្រុមហ៊ុននៅតែបន្តឈូសឆាយតាមអំពើចិត្ត ហើយប្រជាពលរដ្ឋរងផលប៉ះពាល់ត្រូវប្រមូលផ្តុំកម្លាំងទប់ស្កាត់ដោយខ្លួនឯង។

នៅខែមករា ឆ្នាំ២០១៤ សហគមន៍បានសម្រេចចិត្តនាំគ្នាបោះតង់នៅក្បែរទីស្នាក់ការក្រុមហ៊ុនរយៈពេលបីខែ។ ពួកគេមានគោលបំណងទប់ស្កាត់មិនឲ្យក្រុមហ៊ុនធ្វើការឈូសឆាយ។ ក្នុងរយៈពេលនោះ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តព្រះវិហារ បានដឹកនាំកងកម្លាំងមានសមត្ថកិច្ចក្នុងគោលបំណងចាប់សកម្មជនសហគមន៍ដែលបោះតង់ ហើយចោទអ្នកស្រី រឿង ខាន់ ថាជាអ្នកញុះញង់ បះបោរធ្វើឲ្យប៉ះពាល់សង្គម នយោបាយ។ យ៉ាងនេះក្តីអាជ្ញាធរមិនបានចាប់ខ្លួន ឬចាត់វិធានការណាមួយបង្ក្រាបមកលើសហគមន៍ នោះទេ ហើយពួកគាត់បន្តការតវ៉ារហូតដល់ខែមេសា ឆ្នាំ២០១៤។

នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៤ ស្នងការនគរបាលខេត្តព្រះវិហារបានចេញដីកាកោះហៅអ្នកស្រី រឿង ខាន់ និងមនុស្សបីនាក់ផ្សេងទៀតឲ្យចូលបំភ្លឺពី បញ្ហាមួយចំនួន នៅស្នងការដ្ឋាននគរបាលខេត្តព្រះវិហារនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១៤។ អ្នកស្រី ខាន់ បានចូលខ្លួនតាមដីការនៅថ្ងៃទី២ ខែមេសា ប៉ុន្តែការឆ្លើយបំភ្លឺត្រូវបានលើកពេលទៅថ្ងៃទី៤ វិញ ដោយសារមានប្រជាពលរដ្ឋជាងពីររយនាក់បានចូលរួមតវ៉ាគាំទ្រអ្នកស្រី។ នៅថ្ងៃទី៤ ខែមេសា អ្នកស្រី ខាន់ និងប្រជាពលរដ្ឋបានបង្ហាញវត្តមាននៅស្នងការដ្ឋានជាថ្មី ប៉ុន្តែមន្ត្រីនគរបាលបានលើកពេលមិនសាកសួរឡើយ។ នៅថ្ងៃទី៤ ខែឆ្នាំដដែល ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តព្រះវិហារបានចេញដីកាចោទប្រកាន់អ្នកស្រី រឿង ខាន់ និងមនុស្សបីនាក់ផ្សេងទៀតពីបទ "បំផ្លិចបំផ្លាញយ៉ាងឃោរឃៅធ្វើឲ្យខូចខាតអំពៅដោយចេតនា" ទៅតាមពាក្យប្តឹងរបស់លោក ជិន ហ្វុង តំណាងក្រុមហ៊ុន ឡាន ហ្វេង ខេមបូឌា អ៊ីនធឺណេសិនណល លីមីតធីត ដែលចោទអ្នកទាំងបួនថាបានញុះញង់ឲ្យប្រជាពលរដ្ឋទៅដកអំពៅក្រុមហ៊ុនកាលពីថ្ងៃទី១ ខែមេសា។ អ្នកស្រីរឿង ខាន់ បានអះអាងថា ក្រុមហ៊ុនបានភ្ជួរលើដីស្រែប្រជាពលរដ្ឋដែលដាំស្រូវរួច និងដាំអំពៅលើដីនោះទើបពលរដ្ឋទ្រាំមិនបានហើយអ្នកស្រីមិនមានវត្តមានក្នុងហេតុការណ៍នោះទេ តែអ្នកស្រីមិនខ្លាចប្រឈមនឹងតុលាការឡើយ។ ការចោទប្រកាន់មកលើអ្នកស្រីរឿងខាន់ ត្រូវបានលោក ឡុង ស៊ីថា តំណាងអយ្យការអមសាលាដំបូងខេត្តព្រះវិហារបានសម្រេច តម្កល់សំណុំរឿងទុកឥតចាត់ការនៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៤ ដោយពុំបានបញ្ជាក់ពីមូលហេតុអ្វីទាំងអស់។

ថ្វីត្បិតតែសំណុំរឿងនៅតុលាការបានបិទក៏ដោយ ប៉ុន្តែទំនាស់ដីធ្លីនៅមិនទាន់បានដោះស្រាយនៅឡើយ។ ការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពគឺជាបញ្ហាសំខាន់បំផុតក្នុងពេលបច្ចុប្បន្នដែលអ្នកស្រី ខាន់ និងសហគមន៍ទាំងមូលកំពុងតែខ្វះខ្វែង។ ការចុះបញ្ជីដីសមូហភាពមានប្រយោជន៍ច្រើនសម្រាប់ពួកគាត់ដូចជា កាប់ចម្ការប្តូរវេនដំណាំ ព្រៃអារក្ស ព្រៃកប់ខ្មោច រក្សាព្រៃធម្មជាតិ ទីឃ្វាលគោក្របី ដីស្រែចំការ។ អ្នកស្រីរឿង ខាន់ អះអាងថា បញ្ហាដីធ្លីជាបញ្ហាប្រឈមធំបំផុតសម្រាប់គាត់។

អ្នកស្រីខាន់ មានបំណងចង់ឃើញកម្ពុជា ជាប្រទេសមួយដែលមានរដ្ឋាភិបាលចេះគោរព និងការពារសិទ្ធិមនុស្ស ចង់បានភាពសុខសាន្ត ភាពជួបជុំ ទាំងដីធ្លី ព្រៃឈើ ធនធានធម្មជាតិ ធនធានមនុស្ស គ្មានការរំលោភសិទ្ធិមនុស្ស និងចេះគោរពគ្នាទៅវិញទៅមក។

<u>ចប់</u>